**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការបើកផ្ដល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤២)

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៩ ៩៤៦ នាក់ នៃរោងចក្រ សហគ្រាស ទាំង៦៥ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់ទៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្ដល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្ដល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៦០ ០០០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២០ ០០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦០ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៦៥ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្ដល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ពុធ ២កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល

ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០

បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍
ចំនួន ៦៥ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 21 |
| 1 | ក្រុមហ៊ុន ឌី សិតា (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៏ ឌី កម្ពុជា | ភ្នំពេញ |
| 3 | ក្រុមហ៊ុន អេស.វ៉ាយ អ៊ីមប្រយឌើរី ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហ្វូលីង កុំព្យូទរ័ អ៊ីមប្រយឌើរី | ភ្នំពេញ |
| 5 | ក្រុមហ៊ុន អ៊ីស្ទេច ហ្គាមេន | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ឌូហ៊ីស្ត(ខេមបូឌា) | ភ្នំពេញ |
| 7 | ក្រុមហ៊ុន ម៉ាក ប៉ែក (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 8 | ក្រុមហ៊ុន សៅលែន (ខេមបូឌា) | ភ្នំពេញ |
| 9 | ក្រុមហ៊ុន មូនតៃ ខេជេ (ខេមបូឌា) ខូអិលធីឌី | កណ្តាល |
| 10 | ក្រុមហ៊ុន វ៉ាន់កូន អ៊ិនដាសស្រ្ទៀល ខូ អិលធីឌី | កណ្តាល |
| 11 | ក្រុមហ៊ុន ញូអាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត | កណ្តាល |
| 12 | ក្រុមហ៊ុន កៅថេក ហ្គាមេន | កណ្តាល |
| 13 | ក្រុមហ៊ុន ស៊ីលវើរ អេចឆ៏ នីតធីង ឯ.ក | កណ្តាល |
| 14 | ក្រុមហ៊ុន សាន់ហ្រ្គេស ស្ព័ត(ខេមបូឌា) ខូអិលធីឌី | កណ្តាល |
| 15 | ក្រុមហ៊ុន គ្លូរី នីត វែរ អិលធីឌី | កណ្តាល |
| 16 | ក្រុមហ៊ុន ធ្វីនរីន ថេកស្តាយ ឯ.ក | កណ្តាល |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | ក្រុមហ៊ុន អ៊ែដវ្យាយល៍ ស្ទែតថ៏(ខេមបូឌា)ខូ អិលធីឌី | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន វីននីងជ្រាហ្គនទ្បេតជីវ័រ(ខេមបូឌា) ខូអិលធីឌី | កំពង់ស្ពឺ |
| 19 | ក្រុមហ៊ុន ណានវ៉ាង ត្រាវែល ហ្គូដស៍ ឯក | កំពង់ស្ពឺ |
| 20 | ក្រុមហ៊ុន ហឺវ៉ាយហ្សិន អៅដវ(ខេមបូឌា)ខូ,.អិលធីឌី | កំពង់ឆ្នាំង |
| 21 | ក្រុមហ៊ុន ហ៊ែលសា សៅអ៊ិសអេស៊ា ខូអិលលធីឌី | ស្វាយរៀង |
| ខ. វិស័យទេសចរណ៍ | | 44 |
| 22 | សណ្ឋាគារ វ៉ាហ្វិល រ៉ូយ៉ាល់ | ភ្នំពេញ |
| 23 | ក្រុមហ៊ុន វើលដ៏ អិចប្រេស | ភ្នំពេញ |
| 24 | ក្រុមហ៊ុន ភី ធី អ៊ិម ត្រាវែល អ៊ែន ធួរ | ភ្នំពេញ |
| 25 | ក្រុមហ៊ុន ឆេនណល សាយថ៍ ឌីស្ទ្រីប៊្យូសិន | ភ្នំពេញ |
| 26 | ក្រុមហ៊ុន ស្កាយ យីង ត្រាវែល & ធួរ | ភ្នំពេញ |
| 27 | ក្រុមហ៊ុន អេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 28 | ក្រុមហ៊ុន យូ្យ យូ្យ ត្រាវែល អេជេនស៊ី | ភ្នំពេញ |
| 29 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 30 | ក្រុមហ៊ុន ហ្វ៊ូដឡាយហ្វ៍ ឯ.ក | ភ្នំពេញ |
| 31 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 32 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 33 | ក្រុមហ៊ុន កូបេ យៃភែននីស រ៉េស្តូរ៉ែន | សៀមរាប |
| 34 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 35 | ក្រុមហ៊ុន ខ្មែរអង្គរហូថៃលកូអិលធីឌី | សៀមរាប |
| 36 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 37 | សណ្ឋាគារ អង្គរមិរ៉ាខល រីហ្សត និង ស្ប៉ា | សៀមរាប |
| 38 | ក្រុមហ៊ុន អង្គរ ហូលីដេ | សៀមរាប |
| 39 | អាហារដ្ឋានផ្ទះបាយខ្មែរភឿក | សៀមរាប |
| 40 | ក្រុមហ៊ុន មេគ្គារ៉េស៊ីដេន និង ស្ប៉ា | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 41 | សណ្ឋាគារ វីណាហ្គហ្វ អង្គរ | សៀមរាប |
| 42 | ក្រុមហ៊ុន អេប៉ិច ខេមបូឌា ត្រាវ៉េល សឺរវីស | សៀមរាប |
| 43 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 44 | ក្រុមហ៊ុន ផ្លាហ្សា ព្រីមៀ ឡញ (ខេមបូឌា) សាខាសៀមរាប | សៀមរាប |
| 45 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 46 | សណ្ឋាគារ លីនរតនះអង្គរ | សៀមរាប |
| 47 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 48 | ក្រុមហ៊ុន ឡូទុស ប្លង្គ រីសត | សៀមរាប |
| 49 | ក្រុមហ៊ុន ដឹសឃ្វៃរ24 | សៀមរាប |
| 50 | សណ្ឋាគារ សិន្តា មុន្នី | សៀមរាប |
| 51 | សណ្ឋាគារប៉ាស៊ីហ្វិក | សៀមរាប |
| 52 | ក្រុមហ៊ុន អង្គរកែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 53 | ក្រុមហ៊ុន រុក្ខៈ វីរីរ រីសត | សៀមរាប |
| 54 | ក្រុមហ៊ុន បុរី អង្គរ | សៀមរាប |
| 55 | សណ្ឋាគារ ម៉ាល់ បើរី បូទិច អូតែល | សៀមរាប |
| 56 | ភោជនីយដ្ឋាន នារីខ្មែរ | សៀមរាប |
| 57 | សណ្ឋាគារគូលែន | សៀមរាប |
| 58 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 59 | ក្រុមហ៊ុន ជាតិថាតា អង្គរ | សៀមរាប |
| 60 | ក្រុមហ៊ុន មុទិតា រីសត & ស្ប៉ា | សៀមរាប |
| 61 | ក្រុមហ៊ុន អ៊ីបេន ទ្រី ហាត់ | សៀមរាប |
| 62 | ក្រុមហ៊ុន អញ្ចលី បាយ ស៊ីធុន | សៀមរាប |
| 63 | សណ្ឋាគារ បាយ័ន អេវ៉ា ហូថែល ខបភើរេសិន | សៀមរាប |
| 64 | ក្រុមហ៊ុន ចុងក្រោយនៃពិភពលោក | កែប |
| 65 | ក្រុមហ៊ុន ថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |